**គោលនយោបាយសង្ខេប**

**ស្តីពី**

# "តួនាទីរបស់ព្រឹទ្ធសភាក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា"

*ខែសីហា ឆ្នាំ២០១៣*

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា

ឯកសារសង្ខេប..........3

I-សេចក្តីផ្តើមអំពីកំណែទម្រង់វិមជ្ឈការនៅក្នុងប្រទេសកម្ពុជា..........3

II-ជោគជ័យ និងបញ្ហាប្រឈម..........5

១- ការសម្របសម្រួលរវាងតួអង្គសំខាន់ៗ ដើម្បីឆ្ពោះទៅរកកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ..........5

២- ការទំនាក់ទំនងនៅថ្នាក់មូលដ្ឋាន..........6

៣- ការខ្វះចន្លោះភាពច្បាស់លាស់នៃច្បាប់..........6

៤-គណនេយ្យភាព និងការចូលរួម..........7

៥- មូលនិធិសំរាប់អាជ្ញាធរថ្នាក់ក្រោមជាតិ..........7

៦- សមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ..........8

III-តួនាទីរបស់សភាក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ..........9

១- ការលើកកម្ពស់ការអនុវត្តកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈមុខងារជាតំណាងរបស់សភា..........9

២- ការលើកកម្ពស់គោលនយោបាយល្អ និងបរិស្ថានវិជ្ជមានសម្រាប់កំណែទម្រង់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យតាមរយៈមុខងារធ្វើច្បាប់ និងមុខងារតំណាង..........11

IV- សេចក្តីសន្និដ្ឋាន និងអនុសាសន៍..........13

១-ករណីសិក្សា- សមាជិកសភាកម្ពុជារៀបចំកម្រងកិច្ចពិគ្រោះយោបល់ជាសាធារណៈកាលពីដើមឆ្នាំ២០១០..........14

**វិទ្យាស្ថានសភាកម្ពុជា**
**ឯកសារសង្ខេប**
**"តួនាទីរបស់ព្រឹទ្ធសភាក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា"**

---

## I-សេចក្តីផ្តើមអំពីកំណែទម្រង់វិមជ្ឈការនៅក្នុងប្រទេសកម្ពុជា

វិមជ្ឈការត្រូវបានគេឲ្យនិយមន័យថាជាដំណើរការនៃការផ្ទេរការទទួលខុសត្រូវលើការបំពេញកាតព្វកិច្ចសេវាសាធារណៈពីរដ្ឋបាលថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ កំណែទម្រង់វិមជ្ឈការ ត្រូវបានអនុវត្តនៅទូទាំងពិភពលោកអស់រយៈកាលជាងពីរទសវត្សរ៍កន្លងមកហើយ។ កំណែទម្រង់នេះ បានស្តែងឲ្យឃើញនូវសារៈប្រយោជន៍ជាច្រើនដូចជាៈ

- ការពង្រឹងវប្បធម៌លទ្ធិប្រជាធិបតេយ្យនិងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការធ្វើសេចក្តីសំរេចចិត្តជាសាធារណៈ
- ការធ្វើឲ្យមានតុល្យភាពអំណាចនៃរដ្ឋបាលថ្នាល់កណ្តាល តាមរយៈការផ្ទេរអំណាចទៅឲ្យអាជ្ញាធរមូលដ្ឋាន
- ការធ្វើអោយរដ្ឋកាន់តែឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ
- ការលើកកម្ពស់គណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន
- ការផ្តល់ជូននូវសេវានៅថ្នាក់មូលដ្ឋានឲ្យកាន់តែមានប្រសិទ្ធផល និងប្រសិទ្ធភាព ដែលអាចឆ្លើយតបទៅនឹងតំរូវការ និងបញ្ហាជាក់ស្តែងនៅថ្នាក់មូលដ្ឋាន

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលបំណងនៃកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីៈ

- ធ្វើអោយប្រជាធិបតេយ្យ និងគណនេយ្យភាពមានការទទួលស្គាល់កាន់តែខ្លាំង
- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និង
- ផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាឃុំដើម្បីជួយសម្រេចឲ្យបាននូវគោលដៅរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លាននៅមូលដ្ឋានឲ្យកាន់តែមានប្រសិទ្ធផល និងប្រសិទ្ធភាព

ទម្រង់របស់វិមជ្ឈការរួមមានៈ

- **"វិមជ្ឈការសារពើពន្ធ"** : ការផ្ទេរនូវការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុទៅឲ្យអាជ្ញាធរមូលដ្ឋាន ក្នុងទម្រង់ជាការផ្តល់ឲ្យពីរដ្ឋបាលថ្នាក់កណ្តាល និង/ឬ ការផ្តល់អំណាចដើម្បី បង្កើននូវចំណូលផ្ទាល់ខ្លួនទៅឱ្យអាជ្ញាធរទាំងនោះ
- **"វិមជ្ឈការនយោបាយ"**: ការផ្តល់ឲ្យប្រជាពលរដ្ឋ និងអ្នកតំណាងជាប់ឆ្នោតរបស់ពួកគេនូវអំណាចកាន់តែច្រើនក្នុងការធ្វើសេចក្តីសំរេចចិត្តជាសាធារណៈ។ ការអនុវត្តបែបនេះ បញ្ជាក់ថាអ្នកតំណាងខាងនយោបាយរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន(ដូចជា សមាជិកសភា) និងមន្ត្រីថ្នាក់មូលដ្ឋាន អាចស្វែងយល់កាន់តែច្បាស់អំពីតម្រូវការរបស់ម្ចាស់ឆ្នោតខ្លួន។
- **"វិមជ្ឈការតាមបែបប្រជាធិបតេយ្យ"**: ការបោះឆ្នោតនៅថ្នាក់មូលដ្ឋាននៃអាជ្ញាធរថ្នាក់ក្រោមជាតិ(SNAs) ដែលជាអ្នកតំណាង និងជាអ្នកទទួលខុសត្រូវពីថ្នាក់លើទៅ ថ្នាក់ក្រោមចំពោះប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន តួយ៉ាងដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុង ប្រទេសកម្ពុជា
- **"វិមជ្ឈការរដ្ឋបាល"**: ដែលធនធាននៃការទទួលខុសត្រូវ និងការឆ្លើយឆ្លង ត្រូវអនុវត្តដោយផ្ទេរពីថ្នាក់លើមកថ្នាក់ក្រោមពីបណ្តាក្រសួងថ្នាក់ជាតិ ក៏ដូចជាមន្ទីរជំនាញនានានៅថ្នាក់ក្រោមជាតិ (ហៅថា"វិសហមជ្ឈការ") ទៅឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិអនុវត្តដោយឯករាជ្យ ដោយនៅតែមានការទទួលខុសត្រូវចំពោះក្រសួងថ្នាក់ជាតិ (ប្រតិភូកម្ម) ឬផ្តល់ឯករាជ្យភាពដល់អាជ្ញាធរមូលដ្ឋាននូវសិទ្ធិអំណាចទាំងស្រុងក្នុងការធ្វើសេចក្តីសំរេចចិត្ត (ការផ្ទេរអំណាច)។

នៅក្នុងប្រទេសកម្ពុជា ការអភិវឌ្ឍន៏តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(SNDD) ចាប់ផ្តើមដំណើរការចាប់តាំងពីឆ្នាំ២០០១ ជាមួយនិងច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលនៃឃុំ-សង្កាត់ ដែលបានកំណត់អំពីបោះឆ្នោតដោយផ្ទាល់ក្នុងការជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានភារកិច្ចក្នុងការបង្កើតផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងផែនការវិនិយោគប្រចាំឆ្នាំ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈដំណើរការនៃការចូលរួម។ ការផ្ទេរមូលនិធិ ពីអាជ្ញាធរថ្នាក់កណ្តាល គឺត្រូវបានផ្តល់ជូនដល់ក្រុមប្រឹក្សាឃុំ ដើម្បីផ្តល់សេវានានាដែលឆ្លើយតបទៅគម្រោងអាទិភាពនានាដូចបានកំណត់នៅក្នុងផែនការនេះ និងសេវាផ្សេងៗដែលអ្នកផ្តល់សេវាត្រូវផ្តល់ជូនដោយឆ្លើយតបទៅនឹងអាទិភាពនៅថ្នាក់មូលដ្ឋាន ដោយបានទទួលមូលនិធិតាមរយៈការផ្ទេរពីថ្នាក់ជាតិ និងអាចឆ្លើយតបបានតាមរយៈតួអង្គនានា ដូចជាអង្គភាពរបស់ក្រសួងពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា។

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឆ្នាំ២០០៨ (ច្បាប់អង្គការ) បានអនុញ្ញាតឲ្យមានការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដោយបានចាប់ផ្តើមនូវដំណើរការអំពីការរៀបរាប់ និងការកំណត់អំពី មុខងារ និងធនធានសារពើពន្ធ ដែលត្រូវផ្តល់ឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ និងបានកំណត់អំពីទំនាក់ទំនង រវាងខេត្តទាំង២៤ ក្រុង-ស្រុក-ខណ្ឌទាំង១៩៣ និងឃុំ/សង្កាត់(ហៅថា"ឃុំ") ទាំង១៦៣៣ ក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន គេកំពុងផ្តោតលើការកំណែទម្រង់នៅថ្នាក់ស្រុក/ក្រុង និងការដាក់គោលដៅលើកកម្ពស់ការផ្តល់សេវា ដែលអាចសម្រេចបាននូវមាត្រដ្ឋានសេដ្ឋកិច្ចដែលជាតម្រូវការទូទៅនៅទូទាំងឃុំ។

## II-ជោគជ័យ និងបញ្ហាប្រឈម

កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រេចបានសមិទ្ធិ-ផលជាច្រើនក្នុងរយៈពេលដ៏ខ្លី។ ការបោះឆ្នោតនៅថ្នាក់មូលដ្ឋានបាននាំមកនូវស្ថេរភាព គ្រប់គណបក្សនយោបាយបានធ្វើការជាមួយគ្នាដើម្បីបំរើប្រជាជន ហើយទំនុកចិត្តបានកើតមានឡើងរវាងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ តាមរយៈកិច្ចសហការលើការងារគ្រប់គ្រង ការរៀបចំ និងការអនុវត្តគំពេងនៅមូលដ្ឋាន។ ថវិកាសម្រាប់ថ្នាក់ឃុំបានកើនដល់ ២០០លានដុល្លារ ហើយសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ក៏មានការកើនឡើងតាមរយៈគោលការណ៍ "រៀនតាមរយៈការអនុវត្ត"។ ការសម្រេចបាននូវសមិទ្ធផលទាំងនេះ ត្រូវបានកត់សំគាល់ឃើញជាពិសេសនៅក្នុងប្រទេសដែលពុំមានប្រវត្តិយូរអង្វែងនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ឬការចូលរួមក្នុងឆាកនយោបាយពីថ្នាក់ ក្រោមទៅថ្នាក់លើ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិប តេយ្យនៅថ្នាក់ក្រោមជាតិ នៅមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវជំនះឲ្យបាន ហើយកត្តានេះមានសារៈសំខាន់ ណាស់នៅក្នុងដំណាក់កាលបន្ទាប់នៃការធ្វើកំណែទម្រង់។ បញ្ហាទាំងនោះរួមមានៈ

### *១- ការសម្របសម្រួលរវាងតួអង្គសំខាន់ៗ ដើម្បីឆ្ពោះទៅរកកំណែទម្រង់ការអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*

វិមជ្ឈការគឺជាកំណែទម្រង់មួយនៃរដ្ឋបាលទាំងមូល និងមានការចូលរួមពីក្រសួងចំនួន១៥ ផ្សេងៗគ្នាដើម្បបំពេញការងារជាមួយគ្នា ដើម្បីសម្រេចអំពីការទទួលខុសត្រូវ( រឺ "មុខងារ") នៅ ក្នុងដែលគួរតែត្រូវបានផ្តល់ទៅឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិជាមួយ និងធនធានសមស្រប

និងកម្មវិធីនានាក្នុងការកសាងសមត្ថភាព។ ក្រសួងមួយចំនួន មានដំណើរការប្រព្រឹត្តទៅបានយ៉ាងល្អនៅក្នុងការងារនេះ ប៉ុន្តែក៏នៅមានក្រសួងខ្លះទៀត ជួបឧបសគ្គដោយសារតែភាពខ្វះខាតនៃការសម្របសម្រួល នៅឡើយរវាងគោលនយោបាយ និងការធ្វើផែនការរបស់ក្រសួង ព្រមទាំងគោលដៅរបស់វិមជ្ឈការ។ សម្រាប់រយៈពេលវែង ប្រសិនបើបណ្តាក្រសួងទាំងអស់មិនបានបំពេញការងារជាមួយគ្នា នោះប្រាកដជាអាចនាំឲ្យមានភាពខ្វះខាតផ្នែកធនធានសម្រាប់អាជ្ញាធរថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងភារកិច្ចរបស់ខ្លួន។ បញ្ហានេះដែរ ក៏អាចបណ្តាលឲ្យមានការផ្តល់សេវាមិនបានពេញលេញនៅថ្នាក់មូលដ្ឋាន ផងដែរ ដែលតាមធម្មតាមុខងារ និងធនធានពីបណ្តាក្រសួងនានាដំណើរការជាមួយគ្នាដើម្បីផ្តល់សេវា មួយ ដូចជាកម្មវិធីសុខភាពដែលបានផ្តល់ជូនដល់សាលារៀននៅតាមមូលដ្ឋាន។

## *២- ការទំនាក់ទំនងនៅថ្នាក់មូលដ្ឋាន*

ការទំនាក់ទំនងល្អ គឺមានសារៈសំខាន់ខ្លាំងណាស់នៅថ្នាក់មូលដ្ឋាន ដែលអាជ្ញាធរមូលដ្ឋានត្រូវយល់អំពីការទទួលខុសត្រូវរបស់ខ្លួន និងវិធីសាស្ត្រដែលពួកគេអាចប្រើប្រាស់ចំណូលដែលផ្តល់ដល់ពួកគេដើម្បីឆ្លើយតបទៅតម្រូវការនៅថ្នាក់មូលដ្ឋាន។ បញ្ហានេះក៏មានសារៈសំខាន់ផងដែរ ដែលត្រូវឲ្យប្រជាពលរដ្ឋដឹងអំពីអ្វីដែលខ្លួនរំពឹងថានឹងទទួលបានពីអាជ្ញាធរថ្នាក់ក្រោមជាតិ ហើយត្រូវធ្វើយ៉ាងដូចម្តេចដើម្បីចូលរួមក្នុងការធ្វើផែនការ ការផ្តល់សេវា និងការត្រួតពិនិត្យលើសេវាទាំងអស់នោះនៅថ្នាក់មូលដ្ឋាន។ ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន អាចមានការប្រកួតប្រជែងខាងនយោបាយ ឬបញ្ហានយោបាយដែលអាចគ្របដណ្តប់លើការទំនាក់ទំនង និងការសម្របសម្រួល។ ឧទាៈ មេឃុំអាចនឹងមិនសូវជាផ្ទេរសិទ្ធិទៅឲ្យជំទប់ទីមួយ ឬជំទប់ទីពីរ សម្រាប់ការធ្វើជាតំណាងរបស់ខ្លួនទេ។ ជាលទ្ធផល គឺថាការងាររបស់ឃុំអាចរាំងស្ទះដោយសារតែមេឃុំអវត្តមាន។

## *៣- ការខ្វះចន្លោះភាពច្បាស់លាស់នៃច្បាប់*

ច្បាប់វិមជ្ឈការ បានកំណត់អំពីមុខងារ និងការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងទំនាក់ទំនងរវាងពួកគេ។ ប៉ុន្តែទោះជាយ៉ាងណា ការកំណត់មួយចំនួននៅមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេ ហើយនៅតែដាក់ឲ្យអនុវត្ត។ ឧទាៈ ច្បាប់ពុំបានកំណត់ឲ្យបានច្បាស់អំពីតួនាទីរបស់ជំទប់ទីមួយ និងជំទប់ទីពីរ ក៏ដូចជាស្មៀនឃុំផងដែរ។ម្យ៉ាងទៀត នៅពេលដែលមានការប្រគល់អំណាច និងការទទួលខុសត្រូវទៅឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិពីថ្នាក់ជាតិនោះ គឺពុំមានការ

បញ្ជាក់ឲ្យបានច្បាស់លាស់អំពីអាណត្តិ និងមុខងារដាក់លាក់នោះទេ ដែលជាហេតុបណ្តាលឲ្យមានការភ័ន្តច្រឡំក្នុងចំណោមអាជ្ញាធរថ្នាក់ក្រោមជាតិអំពីភារកិច្ចពិតប្រាកដរបស់ពួកគេ។

## *៤-គណនេយ្យភាព និងការចូលរួម*

នៅឯថ្នាក់ឃុំ មន្ត្រីឃុំទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនចំពោះ អាជ្ញាធរថ្នាក់ជាតិ និងអាជ្ញាធរដែលមានឋានានុក្រមខ្ពស់ជាង អាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសទាក់ទងទៅនឹងការប្រើប្រាស់ មូលនិធិ និងធ្វើពីថ្នាក់លើ មកថ្នាក់ក្រោមដើម្បីឲ្យប្រជាពលរដ្ឋធ្វើសេចក្តីសម្រេចចិត្តលើអាទិភាពនៅ មូលដ្ឋាន និងដើម្បីជានា ដល់កិច្ចអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈសិទ្ធិសម្រេចរបស់ពួកគេ។ គណនេយ្យភាពថ្នាក់លើមកថ្នាក់ក្រោម គឺជាបរិការណ៍ថ្មីមួយសម្រាប់បណ្តាប្រទេសជាច្រើនដែលមានប្រវិត្តអភិបាលកិច្ចតាមឋានានុក្រម ហើយទស្សនទាននៃគណនេយ្យភាពនៅមិនទាន់មានការយល់ដឹងពេញលេញនិងអនុវត្តឲ្យបានត្រឹមត្រូវនៅឡើយទេ។ ការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋទាំងដំណើរការនៃការធ្វើផែនការសម្រាប់សេវានៅថ្នាក់មូលដ្ឋាន និងការត្រួតពិនិត្យមើលលើសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានដែលជាគន្លឹះនៃគណនេយ្យភាព និងប្រសិទ្ធផលនៃវិមជ្ឈការជាទូទៅ។ ករណីនេះអាចមានការលំបាកនៅពេលដែលប្រជាពលរដ្ឋមានបទពិសោធន៍តិចតួចក្នុងការប្រែក្លាយឲ្យមានការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។ នៅតាមទីជនបទ ប្រជាពលរដ្ឋ អាចមានពេលវេលាចូលរួម ប៉ុន្តែប្រហែលជាមិនអាចយល់ដឹងអំពីវិធីសាស្ត្រដែលអនុវត្តទៅឲ្យមាន ប្រសិទ្ធភាពនោះទេ ហើយអាចពុំមានទំនុកចិត្តក្នុងការបញ្ចេញនូវគំនិតយោបល់ និងតម្រូវការរបស់ខ្លួនទេ។ នៅតាមទីក្រុងប្រជាពលរដ្ឋអាចមានការយល់ដឹងច្រើនអំពីវិធីសាស្ត្រដែលពួកគេអាចធ្វើឲ្យមានភាពខុសប្លែក ប៉ុន្តែពុំមានពេលវេលាដើម្បីចូលរួម។ បញ្ហានេះបានបង្ហាញអំពីតម្រូវការតុល្យភាពមួយរវាង គោលនយោបាយ និងបទបញ្ញត្តិជាក់លាក់សម្រាប់ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានសម្រាប់វិមជ្ឈការ។ ក្នុងករណីជាច្រើនដែលដំណើរការធ្វើផែនការអាចនៅតែបង្ករឱ្យមានការយល់ច្រឡំដល់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំផងដែរ។

## *៥- មូលនិធិសំរាប់អាជ្ញាធរថ្នាក់ក្រោមជាតិ*

ក្រុមប្រឹក្សាឃុំត្រូវការមូលនិធិគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការផ្តល់សេវានៅថ្នាក់មូលដ្ឋាន តាមរយៈការផ្ទេរ និងការប្រមូលចំណូលពីថ្នាក់ជាតិមកថ្នាក់មូលដ្ឋាន។ មូលនិធិឃុំ/សង្កាត់គឺជាការ ផ្ទេរមូលនិធិពីរដ្ឋបាល ថ្នាក់ជាតិមកថ្នាក់មូលដ្ឋាន ហើយនៅថ្ងៃអនាគតថ្នាក់ស្រុកក៏នឹងមានការផ្តល់

ជូននូវមូលនិធិ សម្រាប់ផ្តល់ សេវានេះផងដែរ។ បច្ចុប្បន្ន មូលនិធិឃុំ/សង្កាត់ តំណាងឲ្យតែចំនួនសមាមាត្រតូចមួយប៉ុណ្ណោះ នៃGDP គឺ ០.២៦%។ ការសិក្សាស្ទាបស្ទង់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន៣៧ បង្ហាញថា ជាមធ្យមអត្រាជាទូទៅ នៃការផ្ទេរពីថ្នាក់ជាតិមកអាជ្ញាធរមូលដ្ឋានដើម្បីឆ្លើយតបទៅការបំពេញភារកិច្ចរបស់ពួកគេគឺមាន ប្រហែលជា ៣% នៃGDP។ បទពិសោធន៍នៃការអនុវត្តល្អៗថ្នាក់អន្តរជាតិបង្ហាញថា គួរតែបញ្ចូលគ្នារវាងការផ្ទេរពីថ្នាក់ជាតិ និងការប្រមូលចំណូលនៅមូលដ្ឋានដើម្បីឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិអនុវត្តទៅបាន ដោយស្វ័យត។ បច្ចុប្បន្ន ទោះបីជាអាណត្តិត្រូវបានកំណត់ដោយច្បាប់ក៏ដោយ ក៏ ប្រភពចំណូលនៅមូលដ្ឋាន គឺប្រមូលបានតិចតួចបំផុត។ ឃុំគួរតែត្រូវបានអនុញ្ញាតឲ្យប្រមូលចំណូលដែលមានតំលៃទាបពីអាជីវករនៅតាមផ្សារ ឬផលិតផលទូទៅនៅក្នុងឃុំ ដែលអាចជួយបង្កើនការប្រមូលចំណូលនៅមូលដ្ឋាន ហើយគួរតែគ្រប់គ្រងលើដំណើរការនៃ ការប្រមូលចំណូលរហូតដល់អាជ្ញាធរថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវកាន់តែច្រើនលើ វិស័យនេះ។

## *៦- សមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ*

ភាគច្រើននៃសមាជិកក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត ជាពិសេសនៅតាមទីជនបទ គឺមានវ័យចំណាស់ និងជាប្រជាពលរដ្ឋដែលមានការគោរពរាប់អាននៅក្នុងសហគមន៍។ លើកលែងតែស្មៀនឃុំដែលភាគច្រើនពួកគេអាចមានបទពិសោធន៍តិចតួច និងអាចរកឃើញគំនិត និងការអនុវត្តថ្មីៗ ដូចជាការប្រឈមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុជាដើម។ បើទោះបីជាមានវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំដែលរៀបចំដោយក្រសួងមហាផ្ទៃ និងតួអង្គផ្សេងៗដូចជាដៃគូអភិវឌ្ឍន៍នានាយ៉ាងណាក៏ដោយ ជានិច្ចកាលការបណ្តុះបណ្តាលទាំងនោះហាក់បីជាមានភាពទូលំទូលាយខ្លាំងពេក ពុំមានការស្វែងយល់ឲ្យបានគ្រប់គ្រាន់ និងមានការខ្វះខាតនូវការពន្យល់លំអិតឲ្យបានច្បាស់លាស់។ សមត្ថភាពគឺជាកត្តាដ៏សំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងអាចមានបញ្ហាមួយចំនួនដែលមានការស្វែងយល់អំពីវិធីសាស្ត្រនៃការផ្តល់ប្រភេទសេវាផ្សេងៗជាជាងប្រភេទជាក់លាក់តែមួយមុខ ដូចជាហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ ជាសក្ខីកម្ម បង្ហាញថាក្រុមប្រឹក្សាឃុំប្រើប្រាស់មូលនិធិឃុំ/សង្កាត់សម្រាប់តែការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងប្រហែលជាពុំមានភាពប្រាកដអំពីវិធីសាស្ត្រនៃការផ្តល់សេវាសង្គមដែលចាំបាច់សម្រាប់ការកាត់បន្ថយភាពក្រីក្រឡើយ។ កត្តានេះអាចមានសារៈសំខាន់ណាស់សម្រាប់កម្មវិធីកសាងសមត្ថភាពដែលអាចឲ្យមន្ត្រីរាជការទៅទស្សនកិច្ច និងសិក្សាស្វែងយល់អំពីអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលមានបទពិសោធន៍អនុវត្តបានល្អៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវា។

## III-តួនាទីរបស់សភាក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ

ដោយផ្អែកលើតម្រូវការសម្រាប់កំណែទម្រង់ទូទៅដូចមានរៀបរាប់ខាងលើ និងបទពិសោធន៍នៃការអនុវត្តល្អៗជាអន្តរជាតិ សភាអាចមានតួនាទីគន្លឹះលើវិស័យមួយចំនួនដូចខាងក្រោមៈ

*១- ការលើកកម្ពស់ការអនុវត្តកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ តាមរយៈមុខងារជាតំណាងរបស់សភា*

សមាជិកសភាអាចមានឥទ្ធិពលយ៉ាងខ្លាំងលើដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈតួនាទីជាតំណាងរបស់ខ្លួន ការរៀបចំនូវការពិគ្រោះយោបល់ជាសាធារណៈនៅថ្នាក់មូលដ្ឋាន និងការតាមដានជាមួយរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាក្រសួងពាក់ព័ន្ធលើបញ្ហាជាក់លាក់នានាដែលបានលើកឡើង។ កម្មវិធីនៃការពិគ្រោះយោបល់ជាសាធារណៈមានគោលបំណងៈ

- ដើម្បីទទួលបានព័ត៌មានពីប្រជាពលរដ្ឋដើម្បីជួយដល់រាជរដ្ឋាភិបាល និងសភាក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- ដើម្បីផ្តល់ជូនប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់ក្រោមជាតិអំពីច្បាប់ និងគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង
- ដើម្បីជួយដោះស្រាយបញ្ហាប្រឈមដែលអាចកើតមានឡើងក្នុងអំឡុងពេលអនុវត្តច្បាប់ស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ប្រសិនបើការអនុវត្តទៅមានប្រសិទ្ធភាព នោះវាមិនត្រឹមតែអាចជួយអ្នកតាក់តែងច្បាប់ក្នុងការបំពេញមុខងារជាតំណាងរបស់ខ្លួនប៉ុណ្ណោះទេ វាក៏អាចជួយផ្តល់ដល់អ្នកតាក់តែងច្បាប់នូវព័ត៌មានដែលអាចជួយដល់ពួកគាត់នៅក្នុងពេលបំពេញតួនាទី និងតួនាទីតាក់តែងច្បាប់ផងដែរ។ ដូចដែល មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាមានកាតព្វកិច្ចផ្តួចផ្តើមរៀបចំ សិក្ខាសាលា ឬវេទិកាដោយមានការចូលរួមពីប្រជាពលរដ្ឋ និងក្រុមប្រឹក្សាអាជ្ញាធរថ្នាក់ក្រោមជាតិដើម្បីស្វែងរកព័ត៌មានស្តីពីបញ្ហានានានៅក្នុងមណ្ឌលបោះឆ្នោត ឬរៀបចំកិច្ចពិគ្រោះយោបល់លើប្រធានបទ ឬបញ្ហាជាក់លាក់ណាមួយ ដោយរួមបញ្ចូលទាំងបញ្ហាប្រឈមមួយចំនួនផងដែរសម្រាប់ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដូចដែលបានរៀបរាប់ខាងលើ។

ផលប្រយោជន៍នៃការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈនៅតាមមណ្ឌលបោះឆ្នោតនីមួយៗសម្រាប់ដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ រួមមានៈ

- ការបង្កើតបណ្តាញរវាងប្រជាពលរដ្ឋ និងសភា និងការបង្ហាញថាសភាអាចដោះស្រាយបញ្ហានៅមូលដ្ឋានបាន។ តាមការចូលរួមក្នុងបញ្ហានៅមូលដ្ឋាន និងការជួយដល់ប្រជាពលរដ្ឋ សមាជិកសភាអាចបង្ហាញថាប្រជាធិបតេយ្យបែបសភានិយមអាចជះឥទ្ធិពលដល់ ការរស់នៅរបស់ប្រជាពលរដ្ឋ។ សមាជិកសភាមួយរូបដែលយល់ដឹងអំពីបញ្ហានៅមូល ដ្ឋានតាមរយៈកិច្ចពិគ្រោះយោបល់ជាសាធារណៈ និងមិនត្រឹមតែបង្កើតការគាំទ្រពីអ្នក បោះឆ្នោតនៅពេលបោះឆ្នោតប៉ុណ្ណោះទេ ថែមទាំងអាចបង្ហាញអំពីគុណតម្លៃរបស់ខ្លួន ជូនដល់គណបក្សថែមទៀតផង មានន័យថាពួកគាត់ហាក់បីដូចជាបានឈានឆ្ពោះ
ទៅរកការធ្វើនយោបាយជាងសមាជិកម្នាក់ដែលរក្សាភាពស្ងៀមស្ងាត់លើបញ្ហាសំខាន់សម្រាប់ម្ចាស់ឆ្នោតរបស់ខ្លួន។
- ការផ្តល់ឱកាសដល់គណៈកម្មការជំនាញរបស់សភាបានស្តាប់អំពីទស្សនៈរបស់សាក្សី និងអ្នកពាក់ព័ន្ធដែលពុំមានលទ្ធភាពធ្វើដំណើរមកដល់រាជធានី។ កត្តានេះអាចនាំឲ្យសមាជិកសភាស្វែងយល់បានកាន់តែច្រើនអំពីប្រភេទនៃសេវាផ្សេងៗដែលជាតម្រូវការក្នុងតំបន់របស់ខ្លួនថាតើតម្រូវការទាំងនោះត្រូវបានដោះស្រាយដោយអាជ្ញាធរនៅថ្នាក់ក្រោមជាតិដែរឬទេ។ បញ្ហានេះអាចជួយដល់ការកំណត់នូវភាពចន្លោះប្រហោងនៃការអនុវត្តច្បាប់ស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈមតិយោបល់របស់អ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់នោះ។
- ការផ្តល់ឲ្យប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់ក្រោមជាតិនូវព័ត៌មានលំអិត និងការឆ្លើយតបទៅនឹងចម្ងល់នានាស្តីពីគោលបំណងនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណើរការ និងការធ្វើច្បាប់។ សមាជិកសភាបានទទួលព័ត៌មាន និងសមត្ថភាពក្នុងការទទួលចម្លើយពីអាជ្ញាធរពាក់ព័ន្ធដែលជានិច្ចកាលពុំបានទៅដល់មន្ត្រីដែលជាប់ឆ្នោតនៅមូលដ្ឋាន និងតំណាងសហគមន៍ផ្សេងៗ។ ការងារនេះអាចធ្វើទៅបានតាមរយៈការិយាល័យប្រចាំភូមិភាគ និងខេត្ត (នាយកដ្ឋានភូមិភាគរបស់ព្រឹទ្ធសភា និងនាយកដ្ឋានមណ្ឌលតំណាងរាស្ត្រខេត្ត-ក្រុងរបស់រដ្ឋសភា) ហើយប្រសិនដំណើរការតាមវិធីនេះបានដោយត្រឹមត្រូវ នោះពិតជាភាពតំណាងឲ្យធនធានសហគមន៍ដ៏មានតម្លៃមួយ។
- ការផ្តល់អំណាចដល់ប្រជាពលរដ្ឋដើម្បីប្រើប្រាស់នូវដំណើរការអភិវឌ្ឍន៍តាមបែបប្រជា

ធិបតេយ្យ និងការធ្វើច្បាប់ដើម្បីប្រែក្លាយឲ្យមានការចូលរួមក្នុងការធ្វើសេចក្ដីសម្រេច នៅថ្នាក់មូលដ្ឋាន។ នៅពេលដែលសភាបំពេញការងារជាមួយមន្ត្រីរាជការ អង្គការក្រៅរដ្ឋាភិបាល និងប្រជាពលរដ្ឋសាមញ្ញ ក្រុមនេះត្រូវបានលើកទឹកចិត្តឲ្យធ្វើការជាមួយគ្នាដើម្បីលើក កម្ពស់ជីវភាពរស់នៅ និងសហគមន៍របស់ខ្លួន។

វាមានសារៈសំខាន់ណាស់សម្រាប់សមាជិកសភាក្នុងការតាមដានអំពីអ្វីដែលបានលើកឡើង នៅក្នុងកិច្ចពិគ្រោះយោបល់ជាសាធារណៈ ដើម្បីឱ្យឲ្យប្រជាពលរដ្ឋនៅមូលដ្ឋានបន្តការចូលរួមក្នុង ការអនុវត្តការងារនាពេលខាងមុខ។ ការងារនេះអាចធ្វើទៅបានតាមរយៈ :

- ការធ្វើលិខិតទៅបណ្ដាក្រសួងពាក់ព័ន្ធមិនលើសពីមួយសប្ដាហ៍ក្រោយកិច្ចពិគ្រោះយោបល់ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើង ក៏ជាការធ្វើលិខិតទៅអាជ្ញាធរថ្នាក់ក្រោមជាតិតាមរយៈការិយាល័យប្រចាំខេត្ត/ភូមិភាគ របស់សភា
- រៀបចំកិច្ចពិភាក្សាតុមូល និងជួបប្រជុំជាមួយក្រសួង និងតំណាងរាជរដ្ឋាភិបាលដើម្បីទទួលបានការបកស្រាយពេញលេញអំពីបញ្ហាដែលបានលើកឡើងក្នុងកិច្ចពិគ្រោះយោបល់ជាសាធារណៈ ធ្វើរបាយការណ៍ឆ្លើយតបអំពីលទ្ធផលជូនទៅម្ចាស់ឆ្នោត និងរៀបចំផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនោះ
- ការប្រើប្រាស់ការិយាល័យប្រចាំខេត្ត/ភូមិភាគ ដើម្បីទំនាក់ទំនងជាមួយអាជ្ញាធរនៅមូលដ្ឋាន និងសាធារណជន

*២- ការលើកកម្ពស់គោលនយោបាយល្អ និងបរិស្ថានវិជ្ជមានសម្រាប់កំណែទម្រង់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យតាមរយៈមុខងារធ្វើច្បាប់ និងមុខងារតំណាង*

រាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវការអ្នកឯកទេស និងជំនួយការដើម្បីបង្កើតការកំណែទម្រង់ និងការតាក់តែងច្បាប់ដើម្បីគាំទ្រដល់ការធ្វើកំណែទម្រង់។ នៅតួនាទីធ្វើច្បាប់របស់ខ្លួន សភាចាំបាច់ត្រូវមានចំណេះដឹងរឹងមាំលើច្បាប់ស្ដីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដើម្បីធានាថាច្បាប់នេះមានភាពច្បាស់លាស់និងត្រឹមត្រូវ។ នៅក្នុងបទបញ្ញាផ្ទៃក្នុងរបស់ព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាត្រូវមានភាពសកម្មនៅក្នុងការចូលរួមក្នុងការធ្វើសេចក្ដីព្រាងច្បាប់ដែលពាក់ព័ន្ធទៅនឹងការ

អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ មាត្រា ៣២ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាបានចែងថា "សមាជិកព្រឹទ្ធសភាគ្រប់រូប មានភារកិច្ចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកពិនិត្យសិក្សាលម្អិត ដោយផ្តោតលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើ ច្បាប់ ឬបញ្ហាទាំងពួង ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខណ្ឌភូមិភាគរបស់ខ្លួន ហើយត្រូវជូនយោបល់០៣ថ្ងៃយ៉ាងយូរមុនគណៈកម្មការប្រជុំ ឬ០១ ថ្ងៃយ៉ាងយូរ បើជាការប្រញាប់។ សភាក៏អាចពិនិត្យសិក្សាលម្អិតលើច្បាប់ថវិកាជាតិ និងលើកជាអនុសាសន៍ស្តីពីកម្រិតនៃមូលនិធិជាតិ ដែលផ្តល់ទៅដល់អាជ្ញាធរថ្នាក់ក្រោមជាតិ។

បទបញ្ជាផ្ទៃក្នុងនេះ ក៏បានបញ្ជាក់ផងដែរថា ព្រឹទ្ធសភាគួរអញ្ជើញរដ្ឋាភិបាល និងតំណាង ក្រសួងអ្នកជំនាញ សាធារណជន និងអ្នកពាក់ព័ន្ធផ្សេងៗ ឲ្យពន្យល់អំពីបញ្ហាសំខាន់ៗ និងផ្តល់ជា អនុសាសន៍ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងដោយម្ចាស់ឆ្នោតរបស់ខ្លួន។ ជាធម្មតា កិច្ចពិគ្រោះ យោបល់ប្រភេទនេះគឺត្រូវរៀបចំដោយគណៈកម្មការជំនាញរបស់សភា។ គណៈកម្មការត្រូវបានប្រើប្រាស់ដោយសមាជិកសភាដើម្បីផ្តល់ព័ត៌មានដល់គណៈកម្មការដែលពួកគេត្រូវផ្តល់ភាពសុក្រឹត្យឲ្យ កាន់តែខ្លាំងទៅលើសេចក្តីស្នើច្បាប់ និងវិសោធនកម្មលើច្បាប់ដែលមានស្រាប់។ ការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈរួមគ្នាដោយមានគណៈកម្មការពីរ ឬច្រើនចូលរួម គឺជាមធ្យោបាយមួយដ៏មានសារៈប្រយោជន៍ក្នុងការសម្របសម្រួលសម្រាប់ការឆ្លើយតបរបស់សភាទៅនឹងបញ្ហាជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងជួយកាត់បន្ថយនូវការលំបាកដែលកើតមានក្នុងការលើកសកម្មភាព និងសំណើខុសគ្នាហើយក៏អាចជួយដល់ការសន្សំសំចៃលើផ្នែកធនធានហិរញ្ញវត្ថុផងដែរ។

បទបញ្ជាផ្ទៃក្នុង ក៏បានចែងផងដែរថា មិនត្រឹមតែគណៈកម្មការជំនាញដែលទទួលខុសត្រូវលើការងារការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានប៉ុណ្ណោះទេដែលត្រូវចូលរួម ប៉ុន្តែគណៈកម្មការជំនាញផ្សេងទៀតរបស់សភា ក៏ត្រូវយកចិត្តទុកដាក់ផងដែរលើបញ្ហាស្តីពីការអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានក្នុងនាមជាប្រធានរួម ដែលចាំបាច់ត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពរបស់ខ្លួន។ អ្នកជំនាញដែលមានបំណងចូលរួមលើការងារនេះ ក៏អាចត្រូវបានអញ្ជើញឲ្យចូលរួមតាមរយៈការរៀបចំកិច្ចពិគ្រោះយោបល់ធម្មតាជាមួយប្រជាពលរដ្ឋនៅក្នុងមណ្ឌលបោះឆ្នោតរបស់សមាជិកសភា ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន និងស្ថាប័នផ្សេងៗដែលនៅជិតប្រជាពលរដ្ឋ ដើម្បីផ្សាភ្ជាប់កំណែទម្រង់ឲ្យកៀកទៅនឹងភាពជាក់ស្តែងនៅថ្នាក់មូលដ្ឋាន បន្ទាប់មកនឹងប្រើប្រាស់នូវតថភាពជាក់ស្តែងនេះដើម្បីជះឥទ្ធិពលដល់ការធ្វើសេចក្តីព្រាង ឬការធ្វើវិសោធនកម្មច្បាប់។

## IV- សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ដោយផ្អែកលើសក្តានុពលដ៏រឹងមាំរបស់សភាក្នុងការលើកកម្ពស់ភាពជោគជ័យនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការបំពេញនូវភារកិច្ចដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន មានអនុសាសន៍មួយចំនួនសម្រាប់សកម្មភាពបន្ថែមដើម្បីពិចារណាលើបញ្ហាប្រឈមមួយចំនួនដែលកើតមាននៅក្នុងដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានដូចខាងក្រោមៈ

- លើកសំណើស្រាវជ្រាវមកវិទ្យាស្ថានសភាកម្ពុជា លើប្រធានបទ/បញ្ហាប្រឈមនានា ដូចបានបញ្ជាក់ជូនក្នុងឯកសារនេះ
- រៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងមណ្ឌលបោះឆ្នោយរបស់ខ្លួន ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពី បញ្ហានៃសមត្ថភាពក្នុងការផ្តល់សេវានៅថ្នាក់មូលដ្ឋាន ប្រភេទនៃការផ្តល់សេវា ភាពគ្រប់គ្រាន់នៃមូលនិធិ សម្រាប់ការផ្តល់សេវា និងលទ្ធភាពនៃការប្រមូលចំណូលនៅថ្នាក់មូលដ្ឋាន ការស្វែង យល់អំពីតួនាទី និងភារកិច្ច វិធីសាស្ត្រនៃការទំនាក់ទំនងរវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ និងកម្រិតនៃភាពសកម្មនៃការចូលរួមរបស់ប្រជាពលរដ្ឋ។
- រៀបចំកិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងអង្គការសង្គមស៊ីវិល ដើម្បីឱ្យយល់កាន់តែច្បាស់អំពីវិធីសាស្ត្រ ដែលពួកគេចូលរួម និងធ្វើអន្តរកម្មជាមួយក្រុមប្រឹក្សាឃុំ និងទំហំដែលក្រុមប្រឹក្សាឃុំ ធ្វើការឆ្លើយតបទៅនឹង កង្វល់ និងសេវាអាទិភាពរបស់ពួកគេ។
- រៀបចំវេទិកានៅថ្នាក់ស្រុក ដោយមានអញ្ជើញតំណាងមកពីថ្នាក់ស្រុក និងខេត្ត និងដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំដែលពាក់ព័ន្ធនៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួន ដើម្បីស្វែងយល់អំពីបទពិសោធន៍នៃការអនុវត្តល្អៗនៅក្នុងឃុំណាមួយ និងពិភាក្សាអំពីបញ្ហារួមណាមួយ។
- រៀបចំការពិគ្រោះយោបល់ជាមួយអ្នកជំនាញ ដោយអញ្ជើញតំណាងក្រសួងដែលពាក់ព័ន្ធនឹងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការសម្របសម្រួលនៅថ្នាក់អន្តរក្រសួង និងដើម្បីឆ្លុះបញ្ចាំងអំពីបញ្ហាពាក់ព័ន្ធដែលបានរកឃើញក្នុងអំឡុងពេលទស្សនកិច្ចនៅតាមមណ្ឌលបោះឆ្នោត។

- ការលើកសំណើឲ្យមានកិច្ចប្រជុំជាទៀងទាត់ជាមួយគណៈកម្មការជាតិដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ដើម្បីជួយដល់សភាឲ្យទទួលបានចំណេះដឹងថ្មីៗអំពីកំណែទម្រង់នាពេលបច្ចុប្បន្ន និងដើម្បីផ្តល់ឱកាសដល់សមាជិកសភាបានផ្តល់យោបល់ណែនាំលើគោលនយោបាយដែលបានបង្កើតឡើង ដោយផ្អែកលើមេរៀនជាពិសោធន៍តាមរយៈសកម្មភាពនៅមូលដ្ឋានរបស់សមាជិកសភា។
- ការលើកសំណើឲ្យមានការផ្លាស់ប្តូរ ឬបន្ថែមលើច្បាប់ ដោយផ្អែកលើបញ្ហាដែលបានលើកឡើងក្នុងពេលចុះទស្សនកិច្ចនៅតាមមណ្ឌលបោះឆ្នោត និងការពិភាក្សាអំពីការផ្លាស់ប្តូរទាំងនេះជាមួយដៃគូពាក់ព័ន្ធថ្នាក់ជាតិ ដូចជាក្រសួងដែលពាក់ព័ន្ធ និងគណៈកម្មការជាតិដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។

### *១-ករណីសិក្សា- សមាជិកសភាកម្ពុជារៀបចំកម្រងកិច្ចពិគ្រោះយោបល់ជាសាធារណៈកាលពីដើមឆ្នាំ២០១០*

ក្នុងរយៈបីខែដំបូងក្នុងឆ្នាំ២០១០ មានកិច្ចពិគ្រោះយោបល់ជាសាធារណៈមួយចំនួនត្រូវបានរៀបចំឡើងនៅតាមបណ្តាខេត្តផ្សេងៗក្នុងប្រទេសកម្ពុជា ដោយផ្តោតលើសារៈសំខាន់អំពីបញ្ហាជាក់ស្តែងដែលបានកំណត់ដោយសមាជិកសភា និងសហគមន៍នៅមូលដ្ឋាន ដោយមានការចូលរួមពីសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា ក៏ដូចជាដៃគូអភិវឌ្ឍន៍នានាដែលបំពេញការងារជាមួយសភាកម្ពុជា។

កាលពីដើមខែមករា ឆ្នាំ២០១០ គណៈប្រតិភូមួយក្រុមដែលមានគណបក្សចម្រុះ ដឹកនាំដោយឯកឧត្តម ជា ដេដ្ឋ ដោយមានការគាំទ្រពីគម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា(CCLSP) UNDP/LEAP និងលេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេស(TCS) បានរៀបចំបេសកកម្មចុះមូលដ្ឋានមួយទៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដើម្បីឲ្យសមាជិកព្រឹទ្ធសភាបានស្វែងយល់ដោយខ្លួនឯងស្តីពី ការងារ និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងខេត្តទាំងនោះ ពាក់ព័ន្ធនឹងការបំពេញការ ងារ និងការអនុវត្តច្បាប់ថវិកា និងពិភាក្សាអំពីវិធីសាស្ត្រ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងក្រុមប្រឹក្សាឃុំ និងការអភិវឌ្ឍន៍នៅមូលដ្ឋាន។ ពេញពាក់កណ្តាលខែចុងក្រោយនៃខែមករា កិច្ចសំណេះសំណាលដែលដឹកនាំដោយលោកជំទាវ ពុំ ស៊ីចាន់ អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ ឡោក ខេង ត្រូវបានរៀបចំឡើងនៅជុំវិញខណ្ឌទាំង៨នៃរាជធានីភ្នំពេញ។ កិច្ចសំណេះសំណាលនេះ

ត្រូវបានរៀបចំឡើងដោយគម្រោង CCLSP រួមជាមួយនាយកដ្ឋានភូមិភាគរបស់ព្រឹទ្ធសភា ក្រុមសមាជិកា និងសមាជិកាក្រុមប្រឹក្សាសង្កាត់។ កិច្ចសំណេះសំណាលនេះ ត្រូវបានរៀបចំឡើងដើម្បីពិភាក្សាអំពីដំណើរការវិវត្តន៍ឆ្ពោះទៅគោលដៅទី៣ ទី៤ ទី៥ នៃគោលដៅអភិវឌ្ឍន៍សហវត្សរកម្ពុជា ដែលពាក់ព័ន្ធទៅនឹងសមភាពយេនឌ័រក្នុងភាពជាតំណាងខាងនយោបាយ មរណភាពកុមារក្នុងប្រទេសកម្ពុជា និងសុខភាពរបស់ស្ត្រី និងកុមារ។ ពិធីសំណេះសំណាលនេះ បានធ្វើឲ្យសមាជិកព្រឹទ្ធសភារកឃើញបញ្ហាប្រឈមនៅមូលដ្ឋានស្តីពីដំណើរការវិវត្តន៍ឆ្ពោះទៅកាន់គោលដៅទាំងនោះ និងដើម្បីពិភាក្សាអំពីកង្វល់ និងបញ្ហាប្រឈមនានានៅរដ្ឋបាលមូលដ្ឋានជាមួយនិងក្រុមប្រឹក្សាសង្កាត់។

ក្នុងខែកុម្ភៈ ឆ្នាំ២០១០ សមាជិកសភាបានចុះទស្សនកិច្ចទៅខេត្តកោះកុង និងខេត្តមណ្ឌលគីរី។ ក្នុងខេត្តកោះកុង គណៈប្រតិភូចម្រុះគណបក្សដែលដឹកនាំដោយ ឯកឧត្តម គង់ សារាជ ប្រធានគណៈកម្មការទី៤នៃព្រឹទ្ធសភា បានជួបជាមួយក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហា និងគម្រោងនានា ដូចជាឥណទាន និងក្រុមសន្សំ គម្រោងអេកូទេសចរណ៍ និងការការពារបរិស្ថាន។ បេសកកម្មនេះក៏បានជួបជាមួយអភិបាលខេត្តដើម្បីលើកឡើងអំពីបញ្ហា និងកង្វល់នានា ហើយក៏បានពិភាក្សាអំពីសកម្មភាពតាមដានបន្តផងដែរ។ បេសកកម្មទៅខេត្តមណ្ឌលគីរីត្រូវរៀបចំឡើងដោយនាយកដ្ឋានកិច្ចការនារី ដោយមានការគាំទ្រពីគម្រោង CCLSP និង Heinrich Boll Stiftung ដែលដឹកនាំដោយលោកជំទាវ មាន សំអាន តំណាងក្រុមសមាជិកាព្រឹទ្ធសភា។ ប្រធានបទដែលបានលើកឡើងនៅក្នុងកិច្ចពិភាក្សាជាមួយខេត្តរួមមាន ដំណើរការ និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំនៅក្នុងខេត្ត ការថែទាំសុខភាពស្ត្រី និងកុមារ និងបញ្ហាយេនឌ័រ។